**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ [illegible] សហវ.[illegible]

# ប្រកាស
# ស្ដីពី
# ការកំណត់កម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្ម

## ឧបនាយករដ្ឋមន្ត្រី
## ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៥ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្ដីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្ដីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការបង្កើតនិងការបំពេញបន្ថែមអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល ឱ្យស្ថិតក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលមាត្រា៥០ មាត្រា៥១ មាត្រា៥២ និងមាត្រា៥៣ នៃអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតនិងការបំពេញបន្ថែមអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្មនិងអង្គភាពលទ្ធកម្ម
- បានឃើញអនុក្រឹត្យលេខ ១៩៣ អនក្រ.បក ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការប្រគល់មុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលឱ្យទៅរដ្ឋបាលរាជធានី ខេត្ត
- បានឃើញប្រកាសលេខ ២៤៩ សហវ.ប្រក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការបង្កើតក្រុមលទ្ធកម្មរបស់អង្គភាពថវិកា
- បានឃើញប្រកាសលេខ ១៨៦៦ សហវ.ប្រក ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការកម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្រ្តលទ្ធកម្ម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ១._**

ត្រូវបានកំណត់កម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្រ្តលទ្ធកម្មទំនិញ សំណង់ និងសេវាកម្ម នៅក្រសួង ស្ថាប័ន អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ រដ្ឋបាលរាជធានី ខេត្ត សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

**ប្រការ២._**

ត្រូវបានកំណត់កម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្រ្តលទ្ធកម្មទំនិញ សំណង់ និងសេវាកម្ម នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

**ប្រការ៣._**

ហាមបំបែកគម្រោងជាគម្រោងតូចៗក្នុងគោលបំណងបំពានវិធីសាស្រ្តលទ្ធកម្ម ដូចខ្លឹមសារដែលមានចែងក្នុងមាត្រា៣៥ នៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ។

**ប្រការ៤._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥.**_

រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ប្រធានសហគ្រាសសាធារណៈ ប្រធានគ្រឹះស្ថានសាធារណៈរដ្ឋបាល អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ប្រធានអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១៤ រោច ២ ខែ អស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៥
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

នៃប្រកាសលេខ ៨៣៣ សហវ.ប្រក.អលសា ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៣

**តារាងកម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្មទំនិញ សំណង់ និងសេវាកម្ម**

**នៅក្រសួង ស្ថាប័ន អង្គភាពថវិការអាណាប័កផ្ទេរសិទ្ធិពេញលេញ រដ្ឋបាលរាជធានី ខេត្ត**

**សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត**

| វិធីសាស្ត្រ | កម្រិតទឹកប្រាក់តាមប្រភេទលទ្ធកម្ម | | |
|---|---|---|---|
| | ទំនិញ | សំណង់ | សេវាកម្ម |
| ការដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ (ដ.ប.អ) | ចាប់ពី ១០.០០០លានរៀល ឡើង | ចាប់ពី ១២.០០០លានរៀល ឡើង | ចាប់ពី ៨.០០០លានរៀល ឡើង |
| ការដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក (ដ.ប.ស) | ចាប់ពី ២០០លានរៀល ដល់ក្រោម ១០.០០០លានរៀល | ចាប់ពី ២០០លានរៀល ដល់ក្រោម ១២.០០០លានរៀល | ចាប់ពី ២០០លានរៀល ដល់ក្រោម ៨.០០០លានរៀល |
| ការដេញថ្លៃមានកម្រិត (ដ.ក) | មិនមានកម្រិតទឹកប្រាក់ | មិនមានកម្រិតទឹកប្រាក់ | មិនមានកម្រិតទឹកប្រាក់ |
| ការពិគ្រោះថ្លៃ (ព.ថ) | ចាប់ពី ៤០លានរៀល ដល់ក្រោម ២០០លានរៀល | ចាប់ពី ៤០លានរៀល ដល់ក្រោម ២០០លានរៀល | ចាប់ពី ៤០លានរៀល ដល់ក្រោម ២០០លានរៀល |
| ការស្ទង់តម្លៃ (ស.ត) | ក្រោម ៤០លានរៀល | ក្រោម ៤០លានរៀល | ក្រោម ៤០លានរៀល |
| លទ្ធកម្មដោយឡែក (ល.ឡ) | មិនមានកម្រិតទឹកប្រាក់ | មិនមានកម្រិតទឹកប្រាក់ | មិនមានកម្រិតទឹកប្រាក់ |

## ឧបសម្ព័ន្ធទី២

នៃប្រកាស៨៣៣ សហវ.ប្រក.អលសា ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៣

**តារាងកម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្មទំនិញ សំណង់ និងសេវាកម្ម**

**នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ**

| វិធីសាស្ត្រ | កម្រិតទឹកប្រាក់តាមប្រភេទលទ្ធកម្ម | | |
|---|---|---|---|
| | ទំនិញ | សំណង់ | សេវាកម្ម |
| ការដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ (ដ.ប.អ) | ចាប់ពី ៤.០០០លានរៀល ឡើង | ចាប់ពី ៥.០០០លានរៀល ឡើង | ចាប់ពី ៣.០០០លានរៀល ឡើង |
| ការដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក (ដ.ប.ស) | ចាប់ពី ២០០លានរៀល ដល់ក្រោម ៤.០០០លានរៀល | ចាប់ពី ២០០លានរៀល ដល់ក្រោម ៥.០០០លានរៀល | ចាប់ពី ២០០លានរៀល ដល់ក្រោម ៣.០០០លានរៀល |
| ការដេញថ្លៃមានកម្រិត (ដ.ក) | មិនមានកម្រិតទឹកប្រាក់ | មិនមានកម្រិតទឹកប្រាក់ | មិនមានកម្រិតទឹកប្រាក់ |
| ការពិគ្រោះថ្លៃ (ព.ថ) | ចាប់ពី ២០លានរៀល ដល់ក្រោម ២០០លានរៀល | ចាប់ពី ៤០លានរៀល ដល់ក្រោម ២០០លានរៀល | ចាប់ពី ២០លានរៀល ដល់ក្រោម ២០០លានរៀល |
| ការស្ទង់តម្លៃ (ស.ត) | ក្រោម ២០លានរៀល | ក្រោម ៤០លានរៀល | ក្រោម ២០លានរៀល |
| លទ្ធកម្មដោយឡែក (ល.ឡ) | មិនមានកម្រិតទឹកប្រាក់ | មិនមានកម្រិតទឹកប្រាក់ | មិនមានកម្រិតទឹកប្រាក់ |